# 1 សន្លឹកព័ត៌មានសំរាប់អ្នកដាំដំណាំលក់តាមទីផ្សារ
## ពាក្យសុំការអភិវឌ្ឍន៍

ពាក្យសុំការអភិវឌ្ឍន៍ គឺតម្រូវសំរាប់សកម្មភាពជាច្រើនយ៉ាងនៅក្នុងការដាំដំណាំលក់តាមទីផ្សារ។ លោកអ្នកមិនត្រូវចាប់ផ្ដើមធ្វើកិច្ចការណាមួយឡើយ លុះត្រាតែលោកអ្នកបានទទួលច្បាប់អនុញ្ញាតយល់ព្រមជាមុនសិន។ តំបន់នៃដីធ្លីរបស់លោកអ្នកនឹងសំរេចទៅលើសកម្មភាពណាមួយដែលតម្រូវលោកអ្នកឲ្យដាក់ពាក្យសុំការអភិវឌ្ឍន៍។

### ការលើកលែងទាំងឡាយ:

មិនមែនគ្រប់ទាំងសកម្មភាពតម្រូវឲ្យមានការដាក់ពាក្យសុំទេ។ ដើម្បីឲ្យបានដឹងថាតើលោកអ្នកត្រូវការដាក់ពាក្យសុំការអភិវឌ្ឍន៍ឬទេ សូមទាក់ទងជាមួយសាលាក្រុងរបស់លោកអ្នកតាមទូរស័ព្ទឬសំបុត្រ។ ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា សូមទូរស័ព្ទលេខ 131 450។

### បុគ្គលិកផែនការ:

លោកអ្នកអាចធ្វើការណាត់ជួបជាមួយបុគ្គលិកផែនការរបស់សាលាក្រុង ដើម្បីពិភាក្សាអំពីគំរោងរបស់លោកអ្នក មុននឹងដាក់ពាក្យសុំជាផ្លូវការ។ ការនេះនឹងជួយលោកអ្នកក្នុងការដាក់ពាក្យសុំឲ្យបានត្រឹមត្រូវ កែលំអឱកាសរបស់លោកអ្នកដើម្បីឲ្យគេយល់ព្រមទទួលពាក្យសុំការអភិវឌ្ឍន៍របស់លោកអ្នក ហើយជួយកាត់បន្ថយនូវពេលវេលាដែលវាត្រូវការដើម្បីទទួលច្បាប់អនុញ្ញាតយល់ព្រម។



NSW DPI, Virginia Brunton



NSW DPI, Steven Honeywood

### បទដ្ឋានការអនុញ្ញាតយល់ព្រម:

ការដាក់ពាក្យសុំអាចប្រើពេលពីចន្លោះ៤អាទិត្យ ទៅ៣ខែ ឬក្នុងករណីយខ្លះ វាត្រូវការពេលយូរជាងនេះ។ ការនេះយោងទៅតាមភាពស្មុគស្មាញនៃពាក្យសុំ ចំនួននៃព័ត៌មានដែលតម្រូវឲ្យដាក់បញ្ចូលថែមទៀត ហើយនិងចំនួនពាក្យសុំដទៃទៀតដែលគេកំពុងចាត់ចែង។ នេះគឺជាការសំខាន់ណាស់ដែលលោកអ្នកត្រូវធ្វើទៅតាមតម្រូវការរបស់សាលាក្រុង។ **បើមិនដូច្នោះទេនោះ គេនឹងមិនធ្វើការសំរេចពាក្យសុំរបស់លោកអ្នកទេ។**

នេះត្រូវបានណែនាំថា លោកអ្នកត្រូវណាត់ពេលជួបសំរាប់ការប្រជុំពាក្យសុំមុនការអភិវឌ្ឍន៍ “pre-development application” មុននឹងដាក់ពាក្យសុំត្រឹមត្រូវ ដើម្បីឲ្យប្រាកដថាលោកអ្នកបានគោរពទៅតាមសេចក្ដីតម្រូវរបស់សាលាក្រុង។ សូមទូរស័ព្ទទៅសាលាក្រុងក្នុងតំបន់របស់លោកអ្នក ហើយសុំនិយាយជាមួយបុគ្គលិកផែនការ។ ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា សូមទូរស័ព្ទលេខ 131 450។

### ច្បាប់អនុញ្ញាតយល់ព្រមរបស់សាលាក្រុង:

ប្រសិនបើលោកអ្នកចាប់ផ្ដើមកិច្ចការមុនពេលសុំច្បាប់អនុញ្ញាតយល់ព្រម ឬប្រសិនបើលោកអ្នកមិនអនុលោមទៅតាមដំណើរការដាក់ពាក្យសុំទេ ឬអ្នកជិតខាងធ្វើការជំទាស់ការដាក់ពាក្យសុំរបស់លោកអ្នកប្រហែលជាត្រូវគេបញ្ជូនទៅក្នុងការប្រជុំសាលាក្រុង។ ករណីយនេះនឹងជួបប្រទះនូវការពិនិត្យពិច័យយ៉ាងហ្មត់ចត់ ហើយនឹងមានការពន្យាពេលក្នុងការធ្វើសេចក្ដីសំរេច។ ការប្រជុំសាលាក្រុងតែងធ្វើឡើងរៀងរាល់២អាទិត្យ ទៅ៤អាទិត្យយោងទៅតាមសាលាក្រុងរបស់លោកអ្នក។ សូមឆែកមើលជាមួយសាលាក្រុងប្រចាំតំបន់របស់លោកអ្នកដើម្បីទទួលយកព័ត៌មានពិស្ដារ។ ការប្ដឹង ឬផាកពិន័យអាចអនុវត្ត ប្រសិនបើលោកអ្នកចាប់ផ្ដើមដោយគ្មានច្បាប់អនុញ្ញាតយល់ព្រមពីសាលាក្រុង។ សូមអានសន្លឹកព័ត៌មានស្ដីអំពីការបែងចែកដីជាតំបន់ និងការប្រើប្រាស់ដីធ្លី ដើម្បីទទួលយកព័ត៌មានបន្ថែមទៀត។

**សូមដាក់ភ្ជាប់ពាក្យសុំរបស់លោកអ្នកជាមួយគំរោងចាត់ចែងចំការ Farm Management Plan។ សំណៅគំរូអាចទទួលយកបានពីក្រសួងឧស្សាហកម្មកែច្នៃវត្ថុធាតុដើម រដ្ឋញូវសៅវែល (NSW Department of Primary Industries) តាមទូរស័ព្ទលេខ 02 4588 2100។**

**សន្លឹកព័ត៌មានសំរាប់អ្នកដាំដំណាំលក់តាមទីផ្សារនេះ** គឺជាផ្នែកនៃលំដាប់ព័ត៌មានគ្រោងឡើងដើម្បីជួយដល់អ្នកដំណាំដែលមកពីសាវតាមិននិយាយភាសាអង់គ្លេស។ ដើម្បីទទួលយកព័ត៌មានច្រើនថែមទៀត សូមទាក់ទងជាមួយសាលាក្រុងក្នុងតំបន់របស់លោកអ្នក។ ប្រសិនបើលោកអ្នកត្រូវការអ្នកបកប្រែភាសា សូមទូរស័ព្ទ TIS លេខ 131 450។

គំរោងការនេះបានទទួលការផ្គត់ផ្គង់ពីរដ្ឋាភិបាលរដ្ឋញូវសៅវែល តាមរយៈមូលនិធិបរិដ្ឋានរបស់ខ្លួន (Environmental Trust)។

ព័ត៌មានដែលចុះនៅក្នុងការចុះផ្សាយនេះសំអាងទៅលើចំណេះដឹង និងការដឹងយល់នៅចំពេលកំពុងសរសេរ (ខែវិច្ឆិកា ឆ្នាំ២០០៧)។ ទោះជាយ៉ាងណាក្ដី ដោយព្រោះតែការចំរើនលើចំណេះដឹង អ្នកប្រើប្រាស់ត្រូវបានរំលឹកប្រាប់ពីសេចក្ដីត្រូវការដើម្បីឲ្យបានប្រាកដថាព័ត៌មានដែលគេពឹងផ្អែកនោះគឺទាន់ពេលថ្មីៗ ហើយត្រូវឆែកមើលព័ត៌មានបច្ចុប្បន្នជាមួយភ្នាក់ងារសមស្របនៃក្រសួងឧស្សាហកម្មកែច្នៃវត្ថុធាតុដើម រដ្ឋញូវសៅវែល ឬជាមួយអ្នកប្រឹក្សាឯករាជ្យនៃអ្នកប្រើប្រាស់ព័ត៌មាននេះ។

NSW DEPARTMENT OF PRIMARY INDUSTRIES

NSW Environmental TRUST